ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ　　ក្រសួងពាណិជ្ជកម្ម　　ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ៤៥០.......សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការហាមឃាត់ការនាំចូលទំនិញដែលប្រើប្រាស់ការងារដោយបង្ខំ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ　　រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម　　រដ្ឋមន្ត្រី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១១ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានដើមកំណើតទំនិញ

- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៣៦ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះកំណត់អំពីបែបបទ នីតិវិធី និងវិធានការក្នុងការហាមឃាត់ការនាំចូលទំនិញពាក់ព័ន្ធនឹងការងារដោយបង្ខំ សំដៅធានាខ្សែច្រវាក់ផ្គត់ផ្គង់ប្រកបដោយការទទួលខុសត្រូវ និងលើកកម្ពស់ភាពប្រកួតប្រជែង។

**ប្រការ២ .-**

ប្រកាសនេះអនុវត្តចំពោះការនាំចូលទំនិញដែលត្រូវបានហាមឃាត់ពាក់ព័ន្ធនឹងការងារដោយបង្ខំ។

**ប្រការ៣ .-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចតទៅ៖

- ការងារដោយបង្ខំ សំដៅដល់រាល់ការងារ ឬសេវាកម្មណា ដែលតម្រូវពីជនណាម្នាក់ដោយការគំរាមកំហែងថានឹងដាក់ទណ្ឌកម្មណាមួយ ហើយដែលជននោះមិនបានស្ម័គ្រចិត្តធ្វើដោយខ្លួនឯង ដូចមានចែងក្នុងច្បាប់ស្តីពីការងារ។
- ទំនិញពាក់ព័ន្ធនឹងការងារដោយបង្ខំ សំដៅដល់ទំនិញដែលជីក ឬទាញយក ផលិត ឬផលិតទាំងស្រុង ឬផ្នែកណាមួយដោយប្រើប្រាស់ការងារដោយបង្ខំ។

**ប្រការ៤ .-**

ត្រូវបានហាមឃាត់ចំពោះការនាំចូល ប្រើប្រាស់ ចរាចរ ឬផ្គត់ផ្គង់ក្នុងព្រះរាជាណាចក្រកម្ពុជានូវទំនិញពាក់ព័ន្ធនឹងការងារដោយបង្ខំ។

**ប្រការ៥ .-**

ក្រុមការងារអន្តរក្រសួង ដែលមានសមាសភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ត្រួតពិនិត្យទំនិញដែលត្រូវបានសង្ស័យថាពាក់ព័ន្ធនឹងការងារដោយបង្ខំ។

ក្រុមការងារអន្តរក្រសួងអាចសហការជាមួយប្រទេសនាំចូលទំនិញពីកម្ពុជា ដើម្បីត្រួតពិនិត្យករណីសង្ស័យលើទំនិញនាំចូលពីកម្ពុជា តាមការចាំបាច់។

**ប្រការ៦ .-**

អ្នកនាំចូលដែលត្រូវបានសង្ស័យថាមានទំនិញពាក់ព័ន្ធនឹងការងារដោយបង្ខំ ត្រូវផ្តល់សេចក្តីបំភ្លឺ ជូនក្រុមការងារអន្តរក្រសួង ក្នុងរយៈពេល១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីការត្រួតពិនិត្យទំនិញដែលត្រូវបានសង្ស័យថាមានពាក់ព័ន្ធនឹងការងារដោយបង្ខំ។

សេចក្តីបំភ្លឺ ត្រូវភ្ជាប់មកជាមួយនូវព័ត៌មាន និងឯកសារ ដូចខាងក្រោម៖

- សំអាងដើមកំណើតទំនិញ និងទីតាំងផលិតកម្ម



ሁ

- ឈ្មោះ និងព័ត៌មានរបស់អ្នកផលិត ឬបុគ្គលពាក់ព័ន្ធក្នុងខ្សែច្រវាក់ផ្គត់ផ្គង់
- ដំណើរការផលិតកម្ម ការទាញយក ការប្រមូលផល ការកែច្នៃ ការផ្ញើ ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀត
- កិច្ចសន្យាទិញលក់ ឯកសារទូទាត់ ឯកសារផ្ទេរកម្មសិទ្ធិ ឬឯកសារពាក់ព័ន្ធផ្សេងទៀត
- របាយការណ៍សវនកម្មអនុលោមភាព របាយការណ៍វាយតម្លៃអនុលោមភាព ឬឯកសារផ្សេងទៀត ដែលអាចបញ្ជាក់អំពីការមិនពាក់ព័ន្ធនឹងការងារដោយបង្ខំ។

**ប្រការ៧ .-**

ក្នុងករណីរកឃើញថាទំនិញនាំចូលមានពាក់ព័ន្ធនឹងការងារដោយបង្ខំ ទំនិញនោះត្រូវបានហាមឃាត់នាំចូល ប្រើប្រាស់ ចរាចរ ឬផ្គត់ផ្គង់ក្នុងកម្ពុជា។

**ប្រការ៨ .-**

ក្នុងករណីរកឃើញដូចមានកំណត់ក្នុងប្រការ៧ ខាងលើ អ្នកនាំចូលត្រូវទទួលរងវិធានការបន្ថែម ដូចខាងក្រោម៖

- ការផ្អាកការធ្វើសកម្មភាពនាំចេញ នាំចូល
- ការផ្អាកការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ
- វិធានការផ្សេងទៀតស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៩ .-**

អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ២ រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០២៦

| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី | រដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
|---|---|---|
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ក្រសួងពាណិជ្ជកម្ម | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | ចម និម្មល | ហេង សួរ |

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ